អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ការបង់ពន្ធជូនរដ្ឋគឺជាកាតព្វកិច្ច របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប
ដើម្បីចូលរួមចំណែកការពារ និង ការអភិវឌ្ឍន៍មាតុភូមិកម្ពុជា

To Pay Tax Is The Obligation For All Cambodian People And
To Contribute To The Defense And Development Of Our Nation!




# បច្ចុប្បន្នភាពច្បាប់ និងបទប្បញ្ញត្តិថ្មីៗ ស្តីពីពន្ធដារ

## រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០

## នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

# មាតិកា

- ពន្ធលើប្រាក់ចំណូល
- ពន្ធកាត់ទុក
- ពន្ធលើប្រាក់បៀវត្ស
- អាករលើតម្លៃបន្ថែម
- ការលើកលែងពន្ធចំពោះវិស័យដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩




# ១. ពន្ធលើប្រាក់ចំណូល

ប្រកាសលេខ ០៩៨ សហវប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# ១.១. វិធានគណនេយ្យ

- **អ្នកជាប់ពន្ធតូច** ត្រូវប្រើវិធានគណនេយ្យសាមញ្ញ
- **អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ**ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា÷
  - ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះ**បានកើតឡើង** ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី
  - ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធ**បានកើតឡើង** លទ្ធផលនៃ**សកម្មភាពសេដ្ឋកិច្ច**ដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និង**ចំនួនទឹកប្រាក់**ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់

# ១.២. ការកែតម្រូវក្រៅគណនេយ្យ

តាមវិធានគណនេយ្យ ប្រាក់ចំណូលពិតគឺជាសមតុល្យនៃគណនី "លទ្ធផលនៃការិយបរិច្ឆេទ" ប៉ុន្តែដោយហេតុមានបទប្បញ្ញត្តិសារពើពន្ធដោយឡែកនោះ លទ្ធផលពិតគណនេយ្យត្រូវតែជាកម្មវត្ថុនៃការកែតម្រូវក្រៅគណនេយ្យដែលមាន**ការបញ្ចូលមកវិញ** និង**ការកាត់ចេញ**ផ្សេងៗ ។

- **ដោយហេតុថាមានបទប្បញ្ញត្តិដោយឡែកខាងពន្ធដារ**ជាធម្មតា ប្រាក់ចំណូលជាប់ពន្ធតាមពន្ធដារ **មិនស្មើគ្នា** នឹងប្រាក់ចំណូលជាប់ពន្ធតាមគណនេយ្យទេ។

# ១.៣. ទ្រព្យសកម្មអាជីវកម្ម

**វៀរលែងតែដីនិងអគារដែលត្រូវអនុវត្តតាមវាក្យខណ្ឌក កថាខណ្ឌ៥ នៃប្រការ៣៦** ទ្រព្យសកម្មអាជីវកម្មរបស់សហគ្រាសឯកបុគ្គល ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម÷

- ម្ចាស់សហគ្រាសឯកបុគ្គលត្រូវកត់ត្រាក្នុងតារាងតុល្យការនៃសហគ្រាសខ្លួននូវចំណែកទាំងអស់នៃទ្រព្យសកម្ម ព្រមទាំងទុនម្ចាស់ទ្រព្យនិងបំណុលដែលជាប់ទាក់ទងនឹងប្រតិបត្តិការអាជីវកម្ម។

**វាក្យខណ្ឌក កថាខណ្ឌ៥ នៃប្រការ៣៦** ក្នុងករណីទ្រព្យសកម្មរយៈពេលវែងត្រូវបានប្រើប្រាស់ក្នុងអាជីវកម្មផងនិងប្រើប្រាស់ក្រៅអាជីវកម្មផង សហគ្រាសត្រូវអនុវត្តដូចខាងក្រោម÷

- ចំពោះសហគ្រាសឯកបុគ្គលឬសហគ្រាសសហកម្មសិទ្ធិ **ការប្រើប្រាស់ដីនិងអគារផ្ទាល់ខ្លួនសម្រាប់ធ្វើអាជីវកម្ម សហគ្រាសមិនត្រូវកត់ត្រាចូលក្នុងតារាងតុល្យការ ហើយក៏មិនត្រូវបានចាត់ទុកជាការជួលដែរ។**
- ក្នុងករណីសហគ្រាសបានកត់ត្រាចូលក្នុងតារាងតុល្យការ **ចំណាយរំលស់មិនត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធឡើយ** ហើយ**មិនត្រូវចាត់ទុកថាបានលក់ទៅនៅពេលឈប់ប្រើប្រាស់ក្នុងអាជីវកម្ម។** សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ ម្ចាស់ដីនិងអគារ រួមបញ្ចូលបុគ្គលទាំងឡាយដែលមានឈ្មោះក្នុងសៀវភៅគ្រួសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

# ១.៥. ពន្ធបង់មុនលើការបែងចែកភាគលាភ

ការបែងចែកភាគលាភចេញពីប្រាក់ចំណូលមុនបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំទៅឱ្យអ្នកចូលហ៊ុនក្នុង
ស្រុក ឬអ្នកចូលហ៊ុនបរទេស សហគ្រាសនោះ***ត្រូវបង់ពន្ធបង់មុនលើការបែងចែកភាគលាភ*** ។

ពន្ធបង់មុនលើការបែងចែកភាគលាភ=

(ភាគលាភបានទទួល/១-អត្រាពន្ធលើប្រាក់ចំណូល) * អត្រាពន្ធអត្រាពន្ធលើប្រាក់ចំណូល

ប្រាក់ពន្ធដែលបានបង់ត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធដែលមានការបែងចែក។ភាគលាភដែលបានបង់ពន្ធ នៅពេលបែងចែកបន្តមិនត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភទៀតទេ។

# ៤-ចំណាយអាជីវកម្ម

ចំពោះចំណាយប្រាក់បៀវត្សដែលត្រូវបើកឱ្យនិយោជិត **សហគ្រាសអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធចរន្តប្រសិនបើប្រាក់បៀវត្សនោះត្រូវបានបើកក្នុងអំឡុងពេល១៨០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់។**

ក្នុងករណីមិនត្រូវបានទូទាត់ក្នុងរយៈពេល១៨០ថ្ងៃ នៃឆ្នាំជាប់ពន្ធបន្ទាប់ ចំណាយនេះត្រូវបញ្ចូលជាចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធចរន្តវិញ។ ប៉ុន្តែ ប្រសិនបើមានការទូទាត់កើតឡើងក្រោយរយៈពេល ១៨០ថ្ងៃ ចំណាយត្រូវបានអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ចំពោះតែការទូទាត់ដែលបានធ្វើឡើងក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះតែប៉ុណ្ណោះ។

# ៤-ចំណាយអាជីវកម្ម

សហគ្រាស ត្រូវធ្វើការកែតម្រូវដោយខ្លួនឯងដោយបញ្ចូលចំណាយដែលមិនបានទូទាត់ខាងលើមកជាចំណូលឆ្នាំជាប់ពន្ធចរន្តវិញ ក្នុងអំឡុងពេល ៣០ថ្ងៃ ក្រោយរយៈពេល ១៨០ថ្ងៃ សហគ្រាស មិនទទួលរងពន្ធបន្ថែមនិងការប្រាក់ទេ។

ក្នុងករណី សហគ្រាសមិនបានកែតម្រូវទាន់ពេលវេលា ពន្ធបន្ថែមនិងការប្រាក់ ត្រូវចាប់ផ្តើម គិតពីខែបន្ទាប់ពីរយៈពេល ១៨០ថ្ងៃ។

# ១.៦. រំលស់សារពើពន្ធ

| កសិកម្មរយៈពេលវែង | ឆ្នាំទទួលផល | អត្រារំលស់ | វិធីសាស្ត្ររំលស់ |
|---|---|---|---|
| ដំណាំកៅស៊ូ | ឆ្នាំទី១ និងទី២ | ៣% | រំលស់ស្មើភាគ |
| | ឆ្នាំទី៣ និងទី៤ | ៤% | រំលស់ស្មើភាគ |
| | ឆ្នាំទី៥ ដល់ ទី១០ | ៥% | រំលស់ស្មើភាគ |
| | ឆ្នាំទី១១ និងទី១២ | ៧% | រំលស់ស្មើភាគ |
| | ឆ្នាំទី១៣ ដល់ទី១៥ | ៦% | រំលស់ស្មើភាគ |
| | ឆ្នាំទី១៦ និងទី១៩ | ៥% | រំលស់ស្មើភាគ |
| | ឆ្នាំទី២០ | សមតុល្យនៅសល់ | រំលស់ស្មើភាគ |
| ដំណាំក្រៅពីកៅស៊ូ | | តាមអាយុកាលនៃការទទួលផល ឬ ៥% មួយណាឆាប់ជាង | រំលស់ស្មើភាគ |
| ការចិញ្ចឹមសត្វ | | តាមអាយុកាលនៃការទទួលផល ឬ ១០% មួយណាឆាប់ជាង | រំលស់ស្មើភាគ |

# ៨- យោងខាត

❖ ខាតបង់កើតឡើងក្នុងឆ្នាំជាប់ពន្ធណាមួយអាចយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី ៥។

❖ **លក្ខខណ្ឌនៃការយោងការខាតបង់មកកាត់ចេញ ÷**

- ការខាតបង់ត្រូវមានចុះក្នុងលិខិតប្រកាសពន្ធប្រាក់ចំណូលប្រចាំឆ្នាំ
- គ្មានការផ្លាស់ប្តូរសកម្មភាពអាជីវកម្ម
- គ្មានការកំណត់ពន្ធជាឯកតោភាគី
- ត្រូវតែមានការបញ្ជាក់អះអាងដោយឯកសារនិងបញ្ជីគណនេយ្យព្រមទាំងនិយ័តកម្មតាមច្បាប់ស្តីពីសារពើពន្ធ។

# ភាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឲ្យធ្វើសវនកម្មគណនេយ្យ

ប្រកាស លេខ ១១៣០ សហវ ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៧

**សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ** ព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល **រហូតដល់ដំណាច់ឆ្នាំ២០២២** តែត្រូវផ្សារភ្ជាប់ជាមួយនឹងអនុលោមភាពសារពើពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចខាងក្រោម÷

១. កាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីគណនេយ្យជាធរមាន

២. ប្រកាសបង់ពន្ធអាករដទៃទៀតជាធរមានទៅតាមកាលកំណត់ និង

៣. ផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធ។

# ២. ពន្ធអប្បបរមា និងលក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវនិងនីតិវិធីនៃការបង់ពន្ធអប្បបរមា

- ពន្ធអប្បបរមាត្រូវកំណត់ស្មើនឹង ១ ភាគរយ នៃផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។

- ពន្ធអប្បបរមាត្រូវបានកំណត់លើសហគ្រាសទាំងឡាយណា ដែលមិនកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ។

## ២. ពន្ធអប្បបរមា និងលក្ខណៈវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យ មិនត្រឹមត្រូវនិងនីតិវិធីនៃការបង់ពន្ធអប្បបរមា (ត)

- ពាក្យ "បញ្ជិកាគណនេយ្យ" សំដៅដល់សំណុំបញ្ជីគណនេយ្យ និងកំណត់ត្រាស្របតាមការតម្រូវរបស់អគ្គនាយកដ្ឋានពន្ធដារ និងស្របតាមស្តង់ដារគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ២. ពន្ធអប្បបរមា និងលក្ខណៈវិនិច្ឆ័យនៃការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវនិងនីតិវិធីនៃការបង់ពន្ធអប្បបរមា (ត)

- ពាក្យ "បញ្ជិកាគណនេយ្យ" សំដៅដល់សំណុំបញ្ជីគណនេយ្យ និងកំណត់ត្រាស្របតាមការតម្រូវរបស់អគ្គនាយកដ្ឋានពន្ធដារ និងស្របតាមស្តង់ដារគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ២. ពន្ធអប្បបរមា និងលក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យ មិនត្រឹមត្រូវនិងនីតិវិធីនៃការបង់ពន្ធអប្បបរមា (ត)

## លក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ មានដូចខាងក្រោម÷

- មិនបានកត់ត្រាបញ្ជីគណនេយ្យបានគ្រប់គ្រាន់តាមលក្ខខណ្ឌ
- មិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ ដូចមានចែងក្នុងមាត្រា៧៧ មាត្រា ៧៨ មាត្រា៧៩ និងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ។
- បានប្រព្រឹត្តការឆ្វេសប្រហែសធ្ងន់ធ្ងរ ដូចមានចែងក្នុងមាត្រា១២៦ នៃច្បាប់ស្តីពីសារពើពន្ធ
- បានធ្វើការគេចវេះពន្ធ ដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់ស្តីពីសារពើពន្ធ
- គ្មានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ក្នុងករណីសហគ្រាសដែលមានផលរបរលើសពី ២ ០០០ លានរៀលក្នុងមួយឆ្នាំ។

*(ប្រកាសលេខ៦៣៨ សហវ.ប្រក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧)*

## ៣- ពន្ធកាត់ទុក : ការលើកលែងពន្ធកាត់ទុក

១. ការទូទាត់ប្រាក់ចំពោះការផ្គត់ផ្គង់សេវាណាមួយដែលមានតម្លៃក្រោម ៥០ ០០០រៀល។

២. ការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុក្នុងចំណោមអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានលើកលែងពីពន្ធកាត់ទុកចំពោះករណីដូចខាងក្រោម÷

- ប្រាក់ចំណូលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់
- ប្រាក់ចំណូលពីការផ្គត់ផ្គង់÷

*កញ្ចប់សូហ្វវែរដែលអនុញ្ញាតឱ្យប្រើប្រាស់ដោយភ្ជាប់លក្ខខណ្ឌ (Shrink-wrap Software)*

*សូហ្វវែរសម្រាប់ប្រើប្រាស់ដោយអង្គភាពមានការកំណត់ (Site License)*

*សូហ្វវែរដែលអាចទាញយកមកប្រើប្រាស់ (Downloadable Software)*

*សូហ្វវែរដែលភ្ជាប់ជាមួយកុំព្យូទ័រ (Software Bundled with Computer Hardware)*

- ប្រាក់ចំណូលពីការជួលចលនទ្រព្យឬអចលនទ្រព្យ

* ការទូទាត់ណាមួយដែលត្រូវបានអនុញ្ញាតឱ្យលើកលែងពន្ធកាត់ទុក *លុះណាតែចំនួនទឹកប្រាក់នោះត្រូវបានកត់ត្រាក្នុង* វិក្កយបត្រមាននិទ្ទេសបានត្រឹមត្រូវ។

# ៣. ពន្ធកាត់ទុក (ត)

ប្រកាសលេខ ៤៧១ សហវ.ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០

## ប្រការ៤- ការលើកទឹកចិត្តពន្ធកាត់ទុក

អ្នកវិនិយោគសាធារណៈត្រូវបានបន្ធូរពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយលើការប្រាក់ និង/ឬភាគលាភ ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល ៣ (បី)ឆ្នាំ គិតពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០១។

# ៣. ពន្ធកាត់ទុក (ត)

ប្រកាសលេខ ៤៧១ សហវ.ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០

**ប្រការ៥- អត្រាពន្ធកាត់ទុកលើការប្រាក់នៃមូលបត្របំណុល**

ពន្ធកាត់ទុកលើការប្រាក់នៃមូលបត្របំណុល ត្រូវកំណត់តាមអត្រា ដូចខាងក្រោម÷

- អត្រា ៦ (ប្រាំមួយ) ភាគរយ ចំពោះការទូទាត់ការប្រាក់ឱ្យដល់អ្នកជាប់ពន្ធនិវាសនជនដូចគ្នានឹងការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់ស្របតាមមាត្រា ២៥ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។
- អត្រា ១៤ (ដប់បួន) ភាគរយ ចំពោះការទូទាត់ការប្រាក់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជន។

# ៣. ពន្ធកាត់ទុក (ត)

យោងតាមប្រការ៣ នៃប្រកាសលេខ ៥២៥ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០

❖ ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលបានខ្ចីប្រាក់ក្នុងស្រុក ឬពីបរទេសសម្រាប់កម្ចីថ្មី វៀរលែងតែប្រាក់កម្ចីចាស់ ឬការស្នើសុំបន្ថែមលើប្រាក់កម្ចីចាស់ ត្រូវ៖

- អនុវត្តការកាត់ទុកប្រាក់ពន្ធចំនួន ៥ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសជន និងអនិវាសនជន សម្រាប់រយៈពេលជាប់ពន្ធពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២០
- អនុវត្តការកាត់ទុកប្រាក់ពន្ធចំនួន ១០ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន សម្រាប់ឆ្នាំ២០២១
- អនុវត្តការកាត់ទុកប្រាក់ពន្ធតាមអត្រាធម្មតា សម្រាប់ឆ្នាំ២០២២តទៅ។

# ៣. ពន្ធកាត់ទុក (ត)

❖ ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលបានខ្ចីប្រាក់ក្នុងស្រុក ឬពីបរទេសសម្រាប់កម្ចីចាស់ ដែលមានសុពលភាព ត្រូវ÷

- អនុវត្តការកាត់ទុកប្រាក់ពន្ធចំនួន ១០ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន សម្រាប់រយៈពេលជាប់ពន្ធពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២០
- អនុវត្តការកាត់ទុកប្រាក់ពន្ធតាមអត្រាធម្មតា សម្រាប់ឆ្នាំ២០២១តទៅ។

# ៤. ពន្ធលើប្រាក់បៀវត្ស

សេចក្តីណែនាំលេខ ០០៦ សហវ.អពដ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ បានកែសម្រួលតារាងអត្រាកំនើន ដូចខាងក្រោម÷

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ | លម្អៀងលើសប្រាក់ពន្ធតាមថ្នាក់ |
|---|---|---|---|---|---|
| ពី | 0៛ | ដល់ | ១ ៣00 000៛ | 0% | 0 ៛ |
| ពី | ១ ៣00 00១៛ | ដល់ | ២000 000៛ | ៥% | ៦៥ 000 ៛ |
| ពី | ២000 00១៛ | ដល់ | ៨ ៥00 000៛ | ១0% | ១៦៥ 000 ៛ |
| ពី | ៨ ៥00 00១៛ | ដល់ | ១២ ៥00 000៛ | ១៥% | ៥៩0 000 ៛ |
| | | លើសពី | ១២ ៥00 000៛ | ២0% | ១ ២១៥ 000 ៛ |

# ៤. ពន្ធលើប្រាក់បៀវត្ស (ត)

សារាចរណែនាំលេខ ០០២ សហវ.អពដ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០

❖ ចំពោះប្រាក់បំណាច់អតីតភាពការងារចាប់ពីឆ្នាំ២០២០ត្រូវអនុវត្តដូចខាងក្រោម÷

- លើកលែងពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បំណាច់អតីតភាពការងារ ដែលមានទឹកប្រាក់មិនលើសពី ៤ ០០០ ០០០ រៀល ក្នុងមួយឆ្នាំ
- ចំពោះប្រាក់បំណាច់អតីតភាពការងារ លើសពី ៤ ០០០ ០០០ រៀល ក្នុងមួយឆ្នាំ ហើយបើកមួយឆ្នាំ២ ដង ត្រូវគណនាពន្ធលើប្រាក់បៀវត្សដូចខាងក្រោម÷
  - ✓ ការបើកលើកទី១ ÷ ត្រូវយកចំនួនទឹកប្រាក់បំណាច់ដែលត្រូវទទួល ដក ២ ០០០ ០០០ រៀល ហើយចំនួននៅសល់ត្រូវបូកបញ្ចូលទៅក្នុងមូលដ្ឋានគណនាពន្ធលើប្រាក់បៀវត្ស
  - ✓ ការបើកលើកទី២ ÷ ត្រូវអនុវត្តដូចការបើកប្រាក់លើកទី១ ដែរ។

# ៤.ពន្ធលើប្រាក់បៀវត្ស (ត)

**សេចក្ដីណែនាំលេខ ៧០១៥ អពដ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០**

❖ អត្រាផ្ដល់ប្រាក់កម្ចីដល់និយោជិត ត្រូវអនុវត្តដូចខាងក្រោម÷

- អត្រាការប្រាក់អប្បបរមានៃកម្ចីដែលផ្ដល់ជូនអតិថិជន ឬអ្នកជំពាក់បំណុលដ៏ទៃទៀត (ដែលមិនមែនជាបុគ្គលទាក់ទិន) ឬ

- អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីប្រចាំឆ្នាំ មុនឆ្នាំជាប់ពន្ធចរន្ត (N-1) ដែលកំណត់ដោយសេចក្ដីជូនដំណឹងរបស់អគ្គនាយកដ្ឋានពន្ធដារ។

# ៥.អាករលើតម្លៃបន្ថែម

## សេចក្តីណែនាំលេខ ១៥៣០១ អពដ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

- ការលក់ទ្រព្យសកម្មរូបីរយៈពេលវែង រួមទាំងការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតម្លៃពិត ឬការផ្ទេរទៅក្នុងសហគ្រាសមួយទៀត ត្រូវគិតអាករលើតម្លៃបន្ថែម ១០%។
- ចំពោះទ្រព្យសកម្មរូបីរយៈពេលវែងដែលឈប់ប្រើប្រាស់÷
  - ✓ ត្រូវចាត់ទុកថាបានលក់ បើទ្រព្យនេះបានទទួលឥណទានអាករ ហើយជាប់អាករលើតម្លៃបន្ថែមតាមតម្លៃទីផ្សារ
  - ✓ មិនត្រូវចាត់ទុកថាលក់ បើសិនជាទ្រព្យនេះមិនបានទទួលឥណទានអាករលើធាតុចូល ហើយមិនជាប់អាករលើតម្លៃបន្ថែមទេ។
- ការលក់ទ្រព្យសកម្មរូបីរយៈពេលវែងរបស់សហគ្រាសដែលធ្វើការផ្គត់ផ្គង់មិនជាប់អាករ ត្រូវជាប់អាករលើតម្លៃបន្ថែម។

# ៦.ការលើកលែងពន្ធចំពោះវិស័យដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩

សេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការបន្ថែមសំដៅជួយដល់វិស័យឯកជន និងកម្មករ-និយោជិត ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ-១៩ (ជុំទី១ ដល់ជុំទី៥)

❖ វិធានការជួយវិស័យទេសចរណ៍

លើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទចំពោះ សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ក្រុងបាវិត និងក្រុងប៉ោយប៉ែត ចាប់ពីខែមីនា ដល់ខែកញ្ញា ឆ្នាំ២០២០។

# ៦. ការលើកលែងពន្ធចំពោះវិស័យដែលរងផលប៉ះពាល់

## ដោយសារជំងឺកូវីដ-១៩ (ត)

ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និងប្រើប្រាស់ប្រព័ន្ធ E-VAT ជារៀងរាល់ខែ។

- វិធានការជួយវិស័យអាកាសចរណ៍

  លើកលែងការបង់ពន្ធអប្បបរមា (Minimum tax) ចាប់ពីខែមីនាដល់ខែកញ្ញា ឆ្នាំ២០២០ ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ ដែលបានចុះបញ្ជីនៅកម្ពុជា។

# សូមអរគុណ